## ចូរតម្រៀបកថាខណ្ឌខាងក្រោមឱ្យទៅ ជា សេចក្ដីអធិប្បាយ (តែងសេចក្ដីបែបពន្យល់)

ការពិតណាស់អវិជ្ជាគឺជាភាពល្ងង់ខ្លៅដែលជាប្រភពនាំឱ្យមានសេចក្ដីវិនាស។ នៅពេលដែលវាកើតឡើងចំពោះ
យើង ឬសម្រាប់ខ្លួនយើង យើងត្រូវចងចាំថា ភាពល្ងង់ខ្លៅគឺជាឫសគល់នៃអំពើអាក្រក់ទាំងអស់។ អ្វីៗដូចជាសំណាងអាក្រក់
គេបោកបញ្ឆោតដោយគូស្នេហ៍របស់អ្នក ថ្នាក់ទាប ការអប់រំ ខ្វះការងារធ្វើ រុញច្រានមនុស្សគ្រប់គ្នាឱ្យឆ្ងាយពីអ្នក ត្រូវបានគេ
ណ្ដេញចេញ ហើយកាន់តែអាក្រក់នឹងកើតឡើងចំពោះយើងជាច្រើន។ ដូចជាមានអំពើហិង្សាក្នុងគ្រួសារ ក៏ដូចជាការខ្វះខាត
សុភមង្គល កង្វះការយល់ដឹងអំពីវិធីជួយគ្នាទៅវិញទៅមកក្នុងការដោះស្រាយវិបត្តិ ការលែងលះរបស់ឪពុកម្ដាយ អាកប្បកិរិយា
ស់បងប្អូនបង្កើត បញ្ហាប្រឈមជាបន្តបន្ទាប់ជាដើម។ ជាចុងក្រោយសម្រាប់អ្នកដែលនៅជុំវិញយើង។ បើនិយាយពីសង្គមវិញ
ប្រទេសសម្បូរទៅដោយអ្នកអវិជ្ជាពិតជាធ្វើឱ្យមានការអភិវឌ្ឍតិចតួចដោយសារខ្វះធនធានមនុស្សក្នុងការរួមចំណែកកសាងជាតិ។
ក់ស្ដែងប្រទេសដែលមានការអភិវឌ្ឍគឺពឹងផ្អែកលើធនធានមនុស្ស។ ប្រសិនបើខ្វះធនធានមនុស្សការអភិវឌ្ឍជាតិមិនអាចរីកច
នបានឡើយ។ ការគ្រប់គ្រងធនធានមនុស្សមិនល្អនឹងប៉ះពាល់ដល់គ្រប់កម្រិតរបស់ស្ថាប័ន ការបណ្ដុះបណ្ដាលមិនគ្រប់គ្រាន់។
ណាស់ក្នុងរបបខ្មែរក្រហមមេដឹកនាំមិនបានគិតដល់ការរៀនសូត្រដល់យុវវ័យជំនាន់ក្រោយ គឺ គ្មានសាលារៀន សម្លាប់អ្នក
ដឹង ឱ្យអ្នកអវិជ្ជាគ្រប់គ្រងប្រជាជននៅតាមតំបន់ ភូមិស្រុក។ កត្តាទាំងនេះបណ្ដាលឱ្យ ប្រទេសជាតិជួបនូវក្តីវិនាសអន្តរាយ។
យើងក្រឡេកមកមើលនៅក្នុងអក្សរសិល្ប៍វិញដូចជារឿងចចក។ តួអង្គចចក ពស់ ដំរី ត្រូវបានចាញ់ការបោកបញ្ឆោត
ភាទន្សាយគ្រាន់តែស្លឹកឈើផ្ទុះៗបញ្ឆោតថាសំបុត្រព្រះឥន្ទ្រវត់យកព្រះអាយុខ្ទាត់ខ្ទាយអស់។ត្រង់នេះបញ្ជាក់បានថាអវិជ្ជា
ងាយចាញ់ឧបាយកល ការបោកបញ្ឆោត ឆាប់ជឿនតាមការអូសទាញទៅរកផ្លូវខុស។
ដូចនេះក្នុងនាមយើងជាសិស្សានុសិស្សត្រូវខិតខំប្រឹងប្រែងរៀនសូត្រឱ្យបានខ្ពង់ខ្ពស់ដើម្បីរំដោះខ្លួនចេញពីភាពអវិជ្ជាដែលជា
មូលហេតុនាំឱ្យយើងវិនាសគ្រប់បែបយ៉ាងពិសេសជាធនធានដ៏សំខាន់ឈានទៅរកការអភិវឌ្ឍជាតិ។

នៅក្នុងលោកយើងនេះមនុស្សគ្រប់រូបតែងឱ្យតម្លៃទៅលើចំណេះវិជ្ជាណាស់។តាំងពីតូចរហូតដល់ធំមនុស្សយើង
តែងតែស្វែងរកចំណេះវិជ្ជាឥតឈប់ឈរ ដើម្បីយកចំណេះដឹងទៅប្រើប្រាស់ក្នុងកិច្ចការងារសម្រាប់ចិញ្ចឹមជីវិត
រស់នៅបានយ៉ាងសុខសាន្ត។ហើយបើកាលណាមនុស្សយើងគ្រប់ៗគ្នាមិនមានចំណេះដឹងក្នុងខ្លួននោះទេយើងច្បាស់
មានសេចក្ដីអន្តរាយដល់ខ្លួនជាក់ជាមិនខាន។

LIVEWORKSHEETS

សុបសេចក្ដីមក មនុស្សគ្រប់គ្នា កាលបើមិនបានរៀនសូត្រ គ្មានការចេះដឹងពិតជានាំឱ្យជួបការលំបាកក្នុងជីវភាពរស់នៅនិងនាំឱ្យជួបនូវសេចក្ដីវិនាសក្នុងជីវិតមនុស្សភាគច្រើន។

ហេតុដូចនេះហើយបានជាមានទស្សនៈមួយបានលើកឡើងថា៖ «អវិជ្ជាជាប្រភពនៃសេចក្ដីវិនាស»។

ឆ្លងតាមការបកស្រាយ ប្រធានបទខាងលើពិតជាមានអត្ថន័យយ៉ាងក្បោះក្បាយនិងស៊ីជម្រៅរួចមកឃើញថាទស្សនៈដែលបានលើកឡើងខាងលើនេះមានតម្លៃអប់រំល្អសម្រាប់យើងទាំងអស់គ្នាឱ្យចេះពិចារណាធ្វើយ៉ាងណាគេចឱ្យផុតពីភាពល្ងង់ខ្លៅ។

តើទស្សនៈដែលបានលើកឡើងខាងលើមានអត្ថន័យយ៉ាងដូចម្ដេចខ្លះ?

ពាក្យ «អវិជ្ជា» មាន អត្ថន័យថា គ្មានចំណេះដឹង សេចក្ដីឥតចំណេះ។ ឯពាក្យ «ប្រភព» សំដៅលើកន្លែងមុនដំបូង ផ្ដើមកំណើត។ ចំណែកឯពាក្យ «វិនាស» គឺសេចក្ដីអន្តរាយ ដែលខូចខាត ដែលបាត់បង់។

ដូចនេះក្នុងនាមយើងជាសិស្សានុសិស្សត្រូវខិតខំប្រឹងប្រែងរៀនសូត្រឱ្យបានខ្ពង់ខ្ពស់ដើម្បីរំដោះខ្លួនចេញពីភាពអវិជ្ជាដែលជាមូលហេតុនាំឱ្យយើងវិនាសគ្រប់បែបយ៉ាងពិសេសជាធនធានដ៏សំខាន់ឈានទៅរកការអភិវឌ្ឍជាតិ។

មុននឹងឈានចូលដល់ការបកស្រាយប្រធានខាងលើ យើងគួរគប្បីយល់នូវពាក្យគន្លឹះមួយចំនួនជាមុនសិន។

ដូចនេះប្រធានបទខាងលើមានអត្ថន័យថាការគ្មានចំណេះដឹងពី ដំបូងអាចធ្វើឱ្យខូចខាតបាត់បង់នូវអ្វីដែលខ្លួនចង់បាន។

LIVEWORKSHEETS

## សេចក្តីអធិប្បាយ

LIVEWORKSHEETS

LIVEWORKSHEETS

LIVEWORKSHEETS